CAMBODIA

*Kingdom of Wonder*

feels the warmth

admin@mot.gov.kh

(+855) 23 884 972

Lot.3A, Street 169, Sangkat Veal Vong, Khan 7 Makara, Phnom Penh, Cambodia

www.tourismcambodia.org

# នីតិវិធីនៃការវាយតម្លៃស្តង់ដា ផ្ទះស្នាក់សហគមន៍




ឆ្នាំ ២០២២

លេខាធិការដ្ឋានគណកម្មាធិការជាតិគ្រប់គ្រង

និងអភិវឌ្ឍសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍

គាំទ្រដោយ៖ គម្រោងទេសចរណ៍ GMS TIIG II No. 3701- CAM (COL)

## គោលបំណង

- គាំទ្រផ្នែកបច្ចេកទេសដល់ជនបង្គោល
- ងាយស្រួលដល់ជនបង្គោលក្នុងការចុះវាយតម្លៃ
- ងាយស្រួលតាមដាន ត្រួតពិនិត្យ និងអនុវត្ត

## សារៈសំខាន់

- ជំរុញសកម្មភាពទេសចរណ៍ក្នុងសហគមន៍ទេសចរណ៍ និងអេកូទេសចរណ៍ ឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តភាព និងមានភាពទាក់ទាញភ្ញៀវ

## នីតិវិធី

- សិក្សាអំពីនិយមន័យនៃពាក្យគន្លឹះក្នុងលក្ខណៈវិនិច្ឆ័យនីមួយៗ
- សិក្សាអំពីលក្ខខណ្ឌតម្រូវនៅក្នុងលក្ខណៈវិនិច្ឆ័យនីមួយៗ
- នីតិវិធីក្នុងការផ្តល់ពិន្ទុជូន



## ដំណើរការនៃការប្រឡងប្រណាំង

- **ដំណាក់កាលទី១៖** ការវាយតម្លៃបឋមដោយម្ចាស់ផ្ទះស្នាក់សហគមន៍ខ្លួនឯងផ្ទាល់ មុនពេលធ្វើការដាក់ពាក្យស្នើសុំមកកាន់អគ្គនាយកដ្ឋានទេសចរណ៍របស់ក្រសួងទេសចរណ៍។
- **ដំណាក់កាលទី២៖** ការដាក់ពាក្យស្នើសុំរបស់ម្ចាស់ផ្ទះស្នាក់សហគមន៍មកកាន់អគ្គនាយកដ្ឋានទេសចរណ៍។
- **ដំណាក់កាលទី៣៖** បន្ទាប់ពីទទួលពាក្យស្នើសុំរបស់ម្ចាស់ផ្ទះស្នាក់ ក្រុមការងារវាយតម្លៃនឹងចុះត្រួតពិនិត្យដល់ទីតាំងផ្ទះស្នាក់ដោយផ្ទាល់។
- **ដំណាក់កាលទី៤៖** របាយការណ៍លទ្ធផលចុះវាយតម្លៃ
- **ដំណាក់កាលទី៥៖** ការប្រកាសផ្តល់ជូនឡាបែលដល់ម្ចាស់ផ្ទះស្នាក់សហគមន៍។

## និតិវិធីក្នុងការផ្តល់ពិន្ទុ



១. ត្រួតពិនិត្យទីតាំងជាក់ស្តែងដោយមន្ត្រីជំនាញ



២. ប្រមូលឯកសារពាក់ព័ន្ធនានា (តារាងភស្តុតាងបញ្ជាក់)



៣. ប្រមូលរូបភាពសកម្មភាពនានា (តារាងភស្តុតាងបញ្ជាក់)

## យន្តការផ្តល់ជូនឡាប៊ិល

**ការទទួលឡាបិល៖** ឡាបិលសម្រាប់ផ្ទះស្នាក់សហគមន៍នឹងផ្តល់ជូនផ្ទះស្នាក់សហគមន៍ណាដែលទទួលបានពិន្ទុស្មើនឹង ៦០% នៃចំនួនពិន្ទុសរុប (ចំនួន **៥៦លក្ខណៈវិនិច្ឆ័យ** នៃលក្ខណៈវិនិច្ឆ័យសរុប)។

**ឡាបិល៖** ឡាបិលផ្ទះស្នាក់សហគមន៍មានសុពលភាពរយៈពេល**០៣ឆ្នាំ**។



## ទិដ្ឋភាពទូទៅផ្ទះស្នាក់កម្ពុជា

កម្មវិធីផ្ទះស្នាក់ ជាទំរង់មួយនៃវិស័យទេសចរណ៍ដែលផ្តល់ឱកាសឱ្យភ្ញៀវទេសចរទទួលបានបទពិសោធន៍អំពីការរស់នៅតាមភូមិជាមួយសហគមន៍នៅជនបទ។ ទន្ទឹមនេះ ផ្ទះស្នាក់ជាកម្មសិទ្ធិរបស់សហគមន៍ និងប្រតិបត្តិដោយសហគមន៍ផ្ទាល់ដើម្បីបំរើឱ្យផលប្រយោជន៍សេដ្ឋកិច្ចទៅដល់សហគមន៍ផ្ទាល់។

ផ្ទះស្នាក់ត្រូវបានគេចាត់ទុកជាផលិតផលទេសចរណ៍មួយដែលចូលរួមចំណែកអភិវឌ្ឍន៍ទេសចរណ៍សហគមន៍ ក៏ដូចជាលើកកម្ពស់ជីវភាពរស់នៅប្រជាពលរដ្ឋសហគមន៍តាមរយៈការបង្កើតឱកាសការងារ ប្រាក់ចំណូលប្រចាំថ្ងៃដោយផ្ទាល់ ជាពិសេសគឺការចូលរួមថែរក្សាសម្បត្តិវប្បធម៌ជាតិ តាមរយៈការរៀបចំផ្ទះស្នាក់សហគមន៍មានទំរង់រចនាបទប្រពៃណីខ្មែរ។

## លក្ខខណ្ឌចូលរួមការប្រឡង

| ល.រ | លក្ខខណ្ឌ |
|---|---|
| ១. | យ៉ាងហោចណាស់មានអ្នកចុះឈ្មោះផ្តល់សេវាផ្ទះស្នាក់ចំនួន ០៥ នៅក្នុងភូមិ |
| ២. | អ្នកផ្តល់សេវាផ្ទះស្នាក់មិនធ្លាប់មានពាក់ព័ន្ធនឹងបទឧក្រិដ្ឋ |
| ៣. | អ្នកផ្តល់សេវាផ្ទះស្នាក់មានសុខភាពល្អ |






## ស្តង់ដាផ្ទះស្នាក់កម្ពុជា



ស្តង់ដាផ្ទះស្នាក់សហគមន៍ រួមមានសូចនាករគោលចំនួន០៩ មានសូចនាករលំអិតចំនួន ២៨ និងមានលក្ខណៈវិនិច្ឆ័យសរុបចំនួន ៩៣។



ស្តង់ដាផ្ទះស្នាក់ជនបទ រួមមានសូចនាករគោលចំនួន០៨ មានសូចនាករលំអិតចំនួន ១៥ និងមានលក្ខណៈវិនិច្ឆ័យសរុបចំនួន៤៤។



ស្តង់ដាផ្ទះស្នាក់ទីក្រុង រួមមានសូចនាករគោលចំនួន០៧ មានសូចនាករលំអិតចំនួន ១៤ និងមានលក្ខណៈវិនិច្ឆ័យសរុបចំនួន៤៧។